## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសុខាភិបាល**

កម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទីពីរ

លេខៈ ១៥៧៣០/១៦ទទវស

ភ្នំពេញ ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៦

## នាយកកម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទីពីរ

## ជំរាបមក

លោក លោកស្រីប្រធានមន្ទីរពេទ្យជាតិ

លោក លោកស្រីប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត

លោក លោកស្រីប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត

លោក លោកស្រីប្រធានការិយាល័យស្រុកប្រតិបត្តិ

លោក លោកស្រីប្រធានមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ

លោក លោកស្រីប្រធានប្រតិបត្តិករមូលនិធិសមធម៌

**កម្មវត្ថុ** : ការផ្ទេរតួនាទី និងការទទួលខុសត្រូវពីប្រតិបត្តិករមូលនិធិសមធម៌ទៅកាន់មន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិ នៅថ្ងៃទី១ កក្កដា ឆ្នាំ២០១៦

**យោង** :
- កិច្ចសន្យាប្រតិបត្តិករមូលនិធិសមធម៌សម្រាប់កំរងលេខ១ ដល់លេខ៣០ ក្រោមកម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទី២ របស់ក្រសួងសុខាភិបាល (MOH/HSSP2)
- ឯកសារគម្រោងលើកកំពស់សមធម៌និងគុណភាពសេវា (H-EQIP)
- កញ្ចប់អត្ថប្រយោជន៍ស្តង់ដាររបស់ក្រសួងសុខាភិបាល និងយន្តការទូទាត់អ្នកផ្តល់សេវាសម្រាប់មូលនិធិសមធម៌ ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៤

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមធ្វើការបញ្ជាក់ពីគោលបំណងរបស់ក្រសួងសុខាភិបាល (MOH) ក្នុងការផ្ទេរប្រព័ន្ធមូលនិធិសមធម៌ពីកម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទី២ របស់ក្រសួងសុខាភិបាល (MOH/HSSP2) ទៅកាន់គម្រោងថ្មីរបស់ក្រសួងសុខាភិបាលដែលហៅថា គម្រោងលើកកំពស់សមធម៌ និងគុណភាពសេវា (MOH/H-EQIP)។ កម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទីពីរ នឹងបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ហើយគម្រោងលើកកំពស់សមធម៌ និងគុណភាពសេវាគ្រោងនឹងចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦។ នៅក្នុងការរៀបចំផ្ទេររវាងគម្រោងទាំងពីរនេះ បុគ្គលិករបស់មន្ទីរពេទ្យខេត្ត រាជធានី មន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិនឹងត្រូវបានផ្តល់ជូននូវការបណ្តុះបណ្តាល និងការតម្រង់ទិសដើម្បីទទួលយកតួនាទី និងការទទួលខុសត្រូវសំរាប់ប្រព័ន្ធមូលនិធិសមធម៌។ តួនាទី និងការទទួលខុសត្រូវទាំងនេះត្រូវបានពណ៌នាពិស្តារនៅផ្នែកខាងក្រោម។

ការបណ្តុះបណ្តាល និងការតម្រង់ទិសសម្រាប់ការផ្ទេរប្រព័ន្ធមូលនិធិសមធម៌ នឹងត្រូវរៀបចំធ្វើក្នុងកំឡុងពេល ៣សប្តាហ៍ នៅក្នុងខែឧសភាឆ្នាំ២០១៦ ដោយយោងតាមតារាងខាងក្រោម។ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល និងការតម្រង់ទិសនេះ មន្ទីរពេទ្យខេត្ត រាជធានី មន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិនឹងត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការប្រតិបត្តិករមូលនិធិសមធម៌ ដើម្បីចាប់ផ្តើមដំណើរការផ្ទេរតួនាទី និងការទទួលខុសត្រូវក្រោមការណែនាំរបស់មន្ទីរសុខាភិបាល ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ តទៅ។

| ល.រ | កន្លែងបណ្តុះបណ្តាល | ចំនួនបុគ្គលិកមន្ទីរពេទ្យ | ចំនួនបុគ្គលិកស្រុកប្រតិបត្តិ | តំណាងប្រតិបត្តិករ | ចំនួនសរុប | ថ្ងៃខែឆ្នាំបណ្តុះបណ្តាល | ក្រុមបណ្តុះបណ្តាល |
|---|---|---|---|---|---|---|---|
| 1 | បាត់ដំបង | 63 | 32 | 78 | 111 | ៣-៥/ឧសភា/២០១៦ | MOH/DPHI & the USAID SHP Project |
| 2 | សៀមរាប | 48 | 20 | 120 | 78 | ៣-៥/ឧសភា/២០១៦ | |
| 3 | កំពត | 66 | 36 | 127 | 120 | ១០-១២/ឧសភា/២០១៦ | |
| 4 | កំពង់ចាម | 73 | 36 | 112 | 127 | ១០-១២/ឧសភា/២០១៦ | |
| 5 | ភ្នំពេញ | 64 | 32 | 94 | 112 | ១៧-១៩/ឧសភា/២០១៦ | |
| 6 | ព្រៃវែង | 52 | 28 | 14 | 94 | ១៧-១៩/ឧសភា/២០១៦ | |
| **Totals** | | **366** | **184** | **92** | **642** | | |

បុគ្គលិកមន្ទីរពេទ្យត្រូវចូលរួមវគ្គបណ្តុះបណ្តាលនៅថ្ងៃខែដែលបានចែងខាងលើដែលមានរយៈពេល ៣ថ្ងៃ បុគ្គលិកស្រុក ប្រតិបត្តិ និងត្រូវចូលរួមវគ្គបណ្តុះបណ្តាលតែចំនួនពីរថ្ងៃដំបូងប៉ុណ្ណោះ។ វាគឺជាការចាំបាច់ដែល មន្ទីរពេទ្យខេត្ត រាជធានី មន្ទីរពេទ្យបង្អែក ស្រុកប្រតិបត្តិជ្រើសរើសបុគ្គលិកដែលនឹងអនុវត្តតួនាទីនិងការទទួលខុសត្រូវដែលបានរៀបរាប់ខាងក្រោម ក្នុងវគ្គបណ្តុះបណ្តាលនេះ ដែលនឹងត្រូវបំពេញការងារដោយផ្ទាល់ជារៀងរាល់ថ្ងៃ។ ឧបសម្ព័ន្ធទីលភ្ជាប់ជាមួយលិខិតនេះគឺជាស្តង់ដាការងារសម្រាប់មន្ទីរពេទ្យខេត្ត រាជធានី ស្រុកប្រតិបត្តិ។ ជាការស្នើរសុំដែលមន្ទីរពេទ្យខេត្ត រាជធានី មន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិចាត់តាំងបុគ្គលិកដើម្បីអោយបានពេញលេញក្នុងការចូលរួមវគ្គបណ្តុះបណ្តាលនេះ។

| | | | | |
|---|---|---|---|---|
| មន្ទីរពេទ្យ (CPA1)<br>បុគ្គលិក៣នាក់ | មន្ទីរពេទ្យ (CPA2)<br>បុគ្គលិក៤នាក់ | មន្ទីរពេទ្យ (CPA3)<br>បុគ្គលិក៥នាក់ | មន្ទីរពេទ្យជាតិ (NH)<br>បុគ្គលិក៦នាក់ | ស្រុកប្រតិបត្តិ<br>បុគ្គលិក២នាក់ |

ក្រសួងសុខាភិបាលទទួលស្គាល់ថា ការផ្ទេរតួនាទី និងការទទួលខុសត្រូវពីប្រតិបត្តិករមូលនិធិសមធម៌ ទៅឲ្យមន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិ គឺជាការធ្វើបច្ចុប្បន្នភាពមួយលើលក្ខខណ្ឌយោងពីមុន ក្រោមកិច្ចសន្យាប្រតិបត្តិករមូលនិធិសមធម៌កំរងក្រុមលេខ ១ ដល់លេខ ៣០។ ក្រសួងសុខាភិបាលស្នើឲ្យប្រតិបត្តិករ ធ្វើការជាមួយមន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យបង្អែកខេត្ត រាជធានី និងស្រុកប្រតិបត្តិ ដើម្បីសម្របសម្រួលការផ្ទេរនេះឲ្យបានសមស្របតាមសេចក្តីណែនាំខាងក្រោម។

នៅក្នុងរយៈពេលអន្តរកាលចាប់ពីថ្ងៃទី ១ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ តួនាទី និងការទទួលខុសត្រូវខាងក្រោមនឹងត្រូវផ្ទេរពីប្រតិបត្តិករមូលនិធិសមធម៌ ទៅកាន់មន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិ។

**១-តួនាទី និងការទទួលខុសត្រូវរបស់មន្ទីរពេទ្យខេត្ត រាជធានី និងមន្ទីរពេទ្យបង្អែក**

**ការចុះឈ្មោះអ្នកជំងឺដែលមានសិទ្ធិទទួលផលប្រយោជន៍ពីមូលនិធិសមធម៌ ៖** ក្នុងរយៈពេលអន្តរកាលនេះ បុគ្គលិកប្រតិបត្តិករមូលនិធិសមធម៌ជាអ្នកទទួលខុសត្រូវក្នុងការចុះឈ្មោះអ្នកជំងឺដែលមានសិទ្ធិទទួលផលប្រយោជន៍ពីមូលនិធិសមធម៌នៅមន្ទីរពេទ្យបង្អែក និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង និងកត់ត្រាអ្នកជំងឺតាមអេឡិចត្រូនិករបស់ក្រសួងសុខាភិបាល (MOH/PMRS) ។ តួនាទីនេះនឹងត្រូវផ្ទេរទៅឲ្យមន្ទីរពេទ្យបង្អែកចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ តទៅ ហើយប្រតិបត្តិ នឹងត្រូវផ្តល់ការគាំទ្រប្រចាំថ្ងៃជាបន្តបន្ទាប់ដល់បុគ្គលិកមន្ទីរពេទ្យបង្អែកនៅក្នុងអំឡុងពេលផ្ទេរនេះដើម្បីអនុវត្តនូវកិច្ចការខាងក្រោមៈ

១. ការបញ្ជាក់អំពីលក្ខណៈសម្បត្តិរបស់អតិថិជនមូលនិធិសមធម៌នៅក្នុងប្រព័ន្ធ MOH/PMRS
២. ការដាក់ឲ្យប្រើប្រាស់ទម្រង់សង្ខេបការព្យាបាលរបស់មូលនិធិសមធម៌
៣. ការបញ្ចូលទិន្នន័យពីទម្រង់សង្ខេបការព្យាបាលរបស់មូលនិធិសមធម៌ក្រោយពេលអ្នកជំងឺចេញពីមន្ទីរពេទ្យ
៤. ការទុកដាក់ឯកសារទម្រង់សង្ខេបការព្យាបាលរបស់មូលនិធិសមធម៌ដោយមានរបៀបរៀបរយដើម្បីសម្រួលដល់ការពិនិត្យឯកសារ និងការធ្វើសវនកម្ម

**ការទូទាត់អត្ថប្រយោជន៍មិនមែនវេជ្ជសាស្ត្រជូនអ្នកជំងឺដែលមានសិទ្ធិទទួលផលប្រយោជន៍ពីមូលនិធិសមធម៌៖** ផ្អែកតាមកញ្ចប់អត្ថប្រយោជន៍ស្តង់ដាររបស់ក្រសួងសុខាភិបាល និងយន្តការទូទាត់អ្នកផ្តល់សេវាសម្រាប់មូលនិធិសមធម៌ ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៤ ក្រសួងសុខាភិបាលស្នើឲ្យប្រតិបត្តិករ ផ្តល់ជូនបុគ្គលិកចាត់តាំងរបស់មន្ទីរពេទ្យបង្អែកនូវប្រាក់បុរេប្រទាន ដើម្បីសម្រួលដល់ការទូទាត់ប្រាក់ឧបត្ថម្ភថ្លៃធ្វើដំណើរ ប្រាក់ឧបត្ថម្ភថ្លៃអាហារសម្រាប់អ្នកកំដរ និងប្រាក់ឧបត្ថម្ភសម្រាប់វិភាគទានបុណ្យសពដល់អ្នកជំងឺដោយបុគ្គលិកមន្ទីរពេទ្យ ដែលនឹងត្រូវទទួលបន្ទុករៀបចំឯកសារ និងគណនេយ្យដោយប្រើប្រាស់ទម្រង់ឯកសារដែលបានកំណត់ក្រោមកម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទី២ផងដែរ។ ប្រតិបត្តិករមូលនិធិសមធម៌ត្រូវផ្តល់ការគាំទ្រដល់បុគ្គលិកមន្ទីរពេទ្យដើម្បីឲ្យពួកគេអាចយល់ និងប្រើប្រាស់ទម្រង់ឯកសារគណនេយ្យ និងរបាយការណ៍ទាំងនេះបាន។ ប្រាក់បុរេប្រទាននេះនឹងត្រូវជាត់ទាត់ដោយមន្ទីរពេទ្យយ៉ាងទៀងទាត់ ហើយប្រតិបត្តិករ នឹងត្រូវរាយការណ៍ពីការចំណាយមូលនិធិសមធម៌ចុងក្រោយទៅកាន់អ្នកអនុវត្តមូលនិធិសមធម៌តាមរយៈទម្រង់ និងនីតិវិធីស្តង់ដារដែលប្រើប្រាស់ដោយគម្រោង MOH/HSSP2 ។

**២-តួនាទី និងការទទួលខុសត្រូវរបស់ស្រុកប្រតិបត្តិ**

ចាប់ពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៦ តទៅ ស្រុកប្រតិបត្តិនីមួយៗក្នុងខេត្តជាអ្នកទទួលខុសត្រូវក្នុងការបញ្ចូលព័ត៌មានពិស្តារនៃវិក្កយបត្រមូលនិធិសមធម៌ពីមណ្ឌលសុខភាពជារៀងរាល់ខែទៅក្នុងប្រព័ន្ធ PMRS របស់ក្រសួងសុខាភិបាល។ បន្ទាប់ពីបានបញ្ចូលព័ត៌មាននេះទៅក្នុងប្រព័ន្ធ PMRS របស់ក្រសួងសុខាភិបាលរួច ស្រុកប្រតិបត្តិបន្តទទួលខុសត្រូវក្នុងការបញ្ជូនវិក្កយបត្រច្បាប់ដើមដែលមានចុះហត្ថលេខាដោយប្រធានស្រុកប្រតិបត្តិ ដើម្បីធ្វើការទូទាត់ចាំបាច់ជូនមណ្ឌលសុខភាព និងផ្ញើវិក្កយបត្រទាំងនេះទៅកាន់អ្នកអនុវត្តមូលនិធិសមធម៌ដែលនឹងត្រូវធ្វើតាម SOP ស្ថិតនៅ ក្រោមគម្រោង MOH/H-EQIP។

**៣-តួនាទី និងការទទួលខុសត្រូវរបស់មន្ទីរសុខាភិបាលខេត្ត រាជធានី**

នៅក្នុងដំណាក់កាលនៃការផ្ទេរមុខងារ ពោលគឺក្រោយពេលបញ្ចប់ការបណ្តុះបណ្តាលភ្លាម រហូតដល់ថ្ងៃទី៣០ មិថុនា ឆ្នាំ២០១៦ មន្ទីរសុខាភិបាលរាជធានីខេត្តជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងលើការអនុវត្តកម្មវិធីមូលនិធិសមធម៌ ផ្តល់ជំនួយបច្ចេកទេស ដល់មូលដ្ឋានសុខភិបាលនិងស្រុកប្រតិបត្តិ ក្នុងការអនុវត្តកម្មវិធីមូលនិធិសមធន៌ប្រកបដោយប្រសិទ្ធភាព។

**៤-តួនាទី និងការទទួលខុសត្រូវរបស់ប្រតិបត្តិករមូលនិធិសមធម៌**

នៅក្នុងអំឡុងពេលអន្តរកាលចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ប្រតិបត្តិករមូលនិធិសមធម៌ក្រោមកិច្ចសន្យាកំរងលេខ ១ ដល់លេខ៣០ នៃគម្រោង MOH/HSSP2 នឹងផ្តល់ជំនួយបច្ចេកទេសប្រចាំថ្ងៃដល់មន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិដើម្បីសម្រួលដល់ការអនុវត្តតួនាទីគ្រប់គ្រងមូលនិធិសមធម៌ដូចបានបរិយាយខាងលើ។ ជាផ្នែកមួយនៃជំនួយបច្ចេកទេសនេះ ក្រសួងសុខាភិបាលស្នើឲ្យប្រតិបត្តិករ ផ្តល់ជូនបុគ្គលិកចាត់តាំងរបស់មន្ទីរពេទ្យបង្អែកនូវប្រាក់បុរេប្រទានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យមានការទូទាត់ប្រាក់ឧបត្ថម្ភថ្លៃធ្វើដំណើរ ប្រាក់ឧបត្ថម្ភថ្លៃអាហារអ្នកកំដរ និងប្រាក់ឧបត្ថម្ភវិភាគទានបុណ្យសព សម្រាប់អ្នកជំងឺដែលមានសិទ្ធិទទួលផលប្រយោជន៍ពីមូលនិធិសមធម៌។ ក្រសួងស្នើថា ប្រាក់បុរេប្រទាននេះគួរមានចំនួនគ្រប់គ្រាន់សម្រាប់ទូទាត់ការចំណាយ

រយៈពេលមួយសប្តាហ៍លើអត្ថប្រយោជន៍មិនមែនវេជ្ជសាស្ត្រទាំងនេះ ដែលបន្ទាប់មក ប្រាក់បុរេប្រទានអាចត្រូវបានទូទាត់ មុននឹងមានការផ្តល់ប្រាក់បុរេប្រទានបន្ទាប់។

នៅក្នុងដំណាក់កាលអន្តរកាលនេះ ជាការចាំបាច់ផងដែរដែលប្រតិបត្តិករមូលនិធិសមធម៌គួរអនុញ្ញាតឲ្យបុគ្គលិកមន្ទីរពេទ្យបង្អែកបានប្រើប្រាស់សម្ភារៈកុំព្យូទ័រដែលផ្តល់ឲ្យក្រោមគម្រោង MOH/HSSP2 សម្រាប់ប្រតិបត្តិការប្រព័ន្ធមូលនិធិសមធម៌។ លើសពីនេះ ប្រតិបត្តិករមូលនិធិសមធម៌ក៏ចាំបាច់ធានាផងដែរថា ស្រុកប្រតិបត្តិបានប្រើប្រាស់កុំព្យូទ័រ និងអ៊ីនធឺណិតសម្រាប់បញ្ចូលទិន្នន័យវិក្កយបត្រមូលនិធិសមធម៌ពីមណ្ឌលសុខភាពជារៀងរាល់ខែផងដែរ។ ទ្រព្យសម្បត្តិ និងបរិក្ខារ (Fixed Assets) ដែលផ្តល់ជូនសម្រាប់ប្រតិបត្តិការប្រព័ន្ធមូលនិធិសមធម៌នឹងនៅតែជាទ្រព្យសម្បត្តិរបស់គម្រោង MOH/HSSP2 ក្រោមការទទួលខុសត្រូវរបស់ប្រតិបត្តិកររហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៦ ។ ក្នុងរយៈពេលអន្តរកាលនេះ ប្រតិបត្តិករត្រូវរៀបចំបញ្ជីទ្រព្យសម្បត្តិ និងបរិក្ខារ (Fixed Assets Listing) ហើយផ្ញើមកកម្មវិធីទ្រទ្រង់សុខាភិបាលជំហានទីពីរដើម្បីផ្ទៀងផ្ទាត់ ដើម្បីប្រគល់ជូនទៅមូលដ្ឋានសុខាភិបាលនិងស្រុកប្រតិបត្តិ ។

ទន្ទឹមនឹងតួនាទី និងការទទួលខុសត្រូវជាក់លាក់ដែលមានចែងនៅក្នុងលិខិតនេះ លក្ខខណ្ឌយោងសម្រាប់ប្រតិបត្តិករមូលនិធិសមធម៌ក្រោមកិច្ចសន្យាកំរងលេខ១ដល់លេខ ៣០ នឹងមិនមានការផ្លាស់ប្តូរអ្វីឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីទទួលជ្រាបជាព័ត៌មាន និងចាត់វិធានការសមស្របដើម្បីទទួលបានប្រសិទ្ធភាពក្នុងការអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់។

សូមលោក លោកស្រីប្រធានទទួលនូវការរាប់អានអំពីខ្ញុំ ។

ក្រសួងសុខាភិបាល
លេខាធិការដ្ឋាន
កម្មវិធីទ្រទ្រង់វិស័យសុខាភិបាល
ជំហានទីពីរ

សាស្ត្រាចារ្យ. អេង ហួត
នាយកកម្មវិធី

ចម្លងជូន ៖
នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល
នាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ
អ្នកអនុវត្តមូលនិធិសមធម៌
ឯកសារ-កាលប្បវត្តិ